## សន្និសិទ្ទ សារព័ត៌មាន

----

# ការផ្សព្វផ្សាយលទ្ធផលចុងក្រោយ
# ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨

ភ្នំពេញ ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ : ថ្ងៃនេះសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសផ្សព្វផ្សាយលទ្ធផលចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨ ដែលជាជំរឿនលើកទីពីរ បន្ទាប់ពីសង្គ្រាមបានបញ្ចប់។ ពិធីនេះប្រព្រឹត្តទៅនៅសាលសន្និសីទ ចតុមុខ។

លទ្ធផលចុងក្រោយ ជំរឿនទូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨ បង្ហាញថាប្រជារាស្ត្ររបស់ប្រទេសកម្ពុជាបានកើនឡើង ១.៩៦ លាននាក់ ក្នុងរយៈពេល ១០ ឆ្នាំមុន គឺកើនពី ១១.៤ លាននាក់ ក្នុងឆ្នាំ ២០០៨ ដល់ ១៣.៤ លាននាក់ ក្នុងឆ្នាំ ២០០៨។ ដង់ស៊ីតេប្រជាជនក៏កើនឡើងពី ៦៤ នាក់ទៅ ៧៥ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ប៉ុន្តែអត្រាកំណើនប្រជាជនប្រចាំឆ្នាំ បានថយចុះពី ២.៤៩% ក្នុងឆ្នាំ ១៩៩៨ មក ១.៥៤% ក្នុងឆ្នាំ ២០០៨។ ទោះបីយ៉ាងណានៅឆ្នាំ១៩៩៨ប្រមាណ ៨.៦ ភាគរយនៃប្រជាជនពិភពលោក ៦.៧ ពាន់លាននាក់រស់នៅអាស៊ីអាគ្នេយ៍ ក្នុងនោះប្រជារាស្ត្ររបស់ប្រទេសកម្ពុជាមាន ២.៣ ភាគរយ ហើយអត្រានេះនៅតែបន្តមកដូចគ្នានៅឆ្នាំ ២០០៨។

នៅពេលដែលអត្រាលទ្ធភាពបង្កើតកូន បានថយចុះមក ៣.១ ការប៉ាន់ស្មានអត្រាមរណៈភាពរបស់ទារកក៏បង្ហាញនូវការថយចុះសមរម្យពី៦៦មក៦០នាក់ក្នុង១.០០០កំណើតរស់នៃអំឡុងឆ្នាំ ២០០៥-២០០៨។ ប៉ុន្តែយ៉ាងណាក៏ដោយ អត្រាមរណៈភាពមាតាមិនមានការប្រែប្រួលទេ ក្នុងរយៈពេល១០ឆ្នាំកន្លងមក ដែលតាមការប៉ាន់ស្មាន គឺ ៤៣៧ ក្នុងឆ្នាំ ២០០០ ៤៧២ ក្នុងឆ្នាំ២០០៥ និង ៤៦១នាក់ ក្នុង ១០០.០០០ កំណើនរស់ក្នុងឆ្នាំ ២០០៨។

តាមការសង្កេតឃើញថាចំនួនប្រជារាស្ត្រចេះអក្សរអាយុ៧ឆ្នាំឡើង បានកើនពី ៥.៧៨ លាន ទៅ ៨.៩៦ លាន់នាក់ ក្នុងរយៈពេល១០ឆ្នាំ បើគិតជាភាគរយក៏កើនពី ៦២.៨០ ភាគរយ ក្នុងឆ្នាំ ១៩៩៨ ទៅ ៧៨.៣៥ ភាគរយក្នុងឆ្នាំ ២០០៨។ ចំណែកអត្រាចេះអក្សររបស់មនុស្សពេញវ័យ ក៏បង្ហាញពីការកើនឡើងយ៉ាងល្អដែរក្នុងអំឡុងឆ្នាំ ១៩៩៨-២០០៨ តែអត្រានេះប្រទេសកម្ពុជាមានកំរិតទាបជាងគេបំផុតបន្ទាប់ពីឡាវ នៅក្នុងតំបន់អាស៊ីអគ្នេយ៏។ ចំនួនប្រជារាស្ត្រអាយុ៦ឆ្នាំឡើងកំពុងរៀននៅសាលាឬបណ្តាគ្រឹស្ថានសិក្សានានាបានកើន ៣៦.២៧ ភាគរយ ក្នុងអំឡុងឆ្នាំ ១៩៩៨-២០០៨ ប៉ុន្តែសមាមាត្រស្រីនៅតែទាបជាងប្រុសទាំងនៅទីប្រជុំជនទាំងនៅជនបទ។

លទ្ធផលចុងក្រោយជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨ មានសារៈសំខាន់ណាស់សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ហើយក៏មានប្រយោជន៍សំរាប់អ្នកតាក់តែងគោលនយោបាយ ក៏ដូចជាអ្នកដឹកនាំនិងអ្នករៀបចំផែនការ។

ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨ បានអនុវត្តន៏ដោយវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ក្រោមការដឹកនាំរបស់គណៈកម្មាធិការជាតិធ្វើជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា និងតាមការណែនាំពីគណៈកម្មការបច្ចេកទេសធ្វើជំរឿន ព្រមទាំងមានការឧបត្ថម្ភដោយរាជរដ្ឋាភិបាលកម្ពុជា អង្គការ **UNFPA** អង្គការ **JICA** រដ្ឋាភិបាលជប៉ុន និងរដ្ឋាភិបាលសាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់។

**ទំនាក់ទំនង**


**ឯកឧត្តម សន ស៊ីថន**

អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ

ទូរស័ព្ទលេខ: ៨៥៥-១៦- ៨៣២-៧៦២

e-mail : sythan@forum.org.kh

**លោកជំទាវ ហង់ លីណា**

អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ

ទូរស័ព្ទលេខ:៨៥៥-១២-៧២៣-១០៧

e-mail : linahang2002@yahoo.com